# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ២៧ ខែ មិនា ឆ្នាំ២០១២

## ជប៉ុនផ្តល់ ១៧,៥៧0 ដុល្លារអាមេរិក សម្រាប់ការគាំទ្រគម្រោងអក្ខរកម្ម

ក្រោមគ្រោងការណ៍នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ជប៉ុន ជំនួយឧបត្ថម្ភឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ(ជំនួយគូសាណូណិ) រដ្ឋាភិបាលជប៉ុននឹងផ្តល់ទឹកប្រាក់សរុបចំនួន ១៧,៥៧0ដុល្លាអាមេរិកដល់សមាគមវប្បធម៌អាស៊ីអាគ្នេយ៍សម្រាប់គម្រោងគាំទ្រអក្ខរកម្ម។ កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខាដោយ លោក តាស៊ុយ៉ា ម៉ាជីដា ទីប្រឹក្សាស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និង បណ្ឌិត ប៉ែន សេដ្ឋារិន តំណាងសមាគមវប្បធម៌អាស៊ីអាគ្នេយ៍នៅស្ថានទូតជប៉ុន។



ដើម្បីផ្តល់នូវការអប់រំអក្ខរកម្មកាន់តែប្រសើរឡើង សមាគមវប្បធម៌អាស៊ីអាគ្នេយ៍ (CAPSEA)ដែលជាអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិមួយនឹងបោះពុម្ពសៀវភៅអំនានភាសាខ្មែរ ព្រមទាំងបកប្រែសៀវភៅរូបភាព៧៤ក្បាលដែលមាន២,០០០ទំព័រពីភាសាជប៉ុនទៅភាសាខ្មែរ។ សៀវភៅអំនានភាសាខ្មែរដែលមានរំលេចដោយពណ៌ទាំងនេះនឹងត្រូវបានចែកជូនថ្នាក់អក្ខរកម្មមួយ និងសាលាបឋមសិក្សាចំនួន១៩។ សៀវភៅរូបភាពដែលបកប្រែពីភាសាជប៉ុននឹងធ្វើឲ្យកុមារ និងប្រជាពលរដ្ឋក្នុងភូមិប្រមាណ៣០០នាក់រីករាយជាមួយការអានរឿងនិទាននៅតាមសាលាបឋមសិក្សា និងភូមិដែលបណ្ណាល័យចល័តរបស់ CAPSEAតែងតែធ្វើដំណើរទៅជារៀងរាល់សប្តាហ៍។ ជាផ្នែកមួយនៃគម្រោងនេះផងដែរ កៅអីបត់ និងតុចំនួន១០ក៏នឹងត្រូវបានបំពាក់នៅក្នុងថ្នាក់អក្ខរកម្មរបស់CAPSEA។ គម្រោងនេះនឹងរួមចំណែកដល់ការលើកស្ទួយវិស័យអក្ខរកម្ម ពិសេសសម្រាប់កុមារតូចៗនៅកម្ពុជា។

កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ ( *ជំនួយគូសាណូណិ*) របស់រដ្ឋាភិបាលជប៉ុនបានចាប់ផ្តើមតាំងពីឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍន៍ និងស្តាបនាប្រទេសឡើងវិញនៅតាមកំរិតមូលដ្ឋាន។ គម្រោងជំនួយនេះមានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា ភាពក្រីក្រ និងភាពអកុសលដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការចិញ្ចឹមជិវិត និងសេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជាជួយជុំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង ៤៧.៥លានដុល្លាអាមេរិកដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាលដើម្បីអនុវត្តគម្រោងចំនួន ៤៧២គម្រោងនៅទូទាំងប្រទេស។




ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០

អ៊ីមែល: eco.jpn@.pp.mofa.go.jp

គេហទំព័រ: http://www.kh.emb-japan.go.jp